ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

L202412230355TD2301

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## កិច្ចពិភាក្សាស្តីពីការពង្រឹងសមត្ថភាព គ្រូបង្រៀនមុខវិជ្ជាពន្ធដារ នៅតាមគ្រឹះស្ថានឧត្តមសិក្សា

ថ្ងៃសុក្រ ៥ រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
អគ្គនាយកដ្ឋានពន្ធដារ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៤




នាព្រឹកថ្ងៃសុក្រ ៥ រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៤ នៅសាលាជាតិពន្ធដារ បានរៀបចំកិច្ចពិភាក្សាស្តីពី "ការពង្រឹងសមត្ថភាពគ្រូបង្រៀនមុខវិជ្ជាពន្ធដារ នៅតាមគ្រឹះស្ថានឧត្តមសិក្សា" រវាងសាលាជាតិពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ និងសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា ក្រោមអធិបតីភាពលោក **ស៊ុន ឌុទ្ធី** នាយកសាលាជាតិពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ និងឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** ប្រធានសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា ដោយមានការចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីនៃសាលាជាតិពន្ធដារ និងថ្នាក់ដឹកនាំ សាស្ត្រាចារ្យនៃសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជាសរុបចំនួន **៧៧** នាក់ ដែលអញ្ជើញមកពីបណ្តាសាកលវិទ្យាល័យ និងគ្រឹះស្ថានសិក្សាទូទាំងប្រទេស។

ជាកិច្ចចាប់ផ្តើម លោក **ស៊ុន ឌុទ្ធី** នាយកសាលាជាតិពន្ធដារ បានមានមតិសំណេះសំណាលដោយបានស្វាគមន៍យ៉ាងកក់ក្តៅវត្តមានរបស់ឯកឧត្តម លោកជំទាវ សាកលវិទ្យាធិការ នាយក សាស្ត្រាចារ្យ លោក លោកស្រី ទាំងអស់ ដែលបានចូលរួមក្នុងកិច្ចពិភាក្សានេះ និងបានគូសរំលេចអំពីការយកចិត្តទុកដាក់របស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងការចូលរួមអនុវត្តភាពជាដៃគូល្អ រវាងអគ្គនាយកដ្ឋានពន្ធដារ និងសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា ជាពិសេសលើវិស័យអប់រំនេះ ក្រោមការចង្អុលបង្ហាញ

ដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ និងស្របតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ឈ្លាសវៃបំផុតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ បន្ថែមពីនេះលោកនាយកសាលាជាតិពន្ធដារបានគូសបញ្ជាក់អំពីគោលបំណងនៃកិច្ចពិភាក្សានេះ គឺដើម្បីបង្កើនភាពជាដៃគូ រវាងអគ្គនាយកដ្ឋានពន្ធដារ និងសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា ពង្រឹងសមត្ថភាពគ្រូបង្រៀនលើមុខវិជ្ជាពន្ធដារដើម្បីឱ្យមានសង្គតិភាព និងឯកភាពគ្នា ទាំងការបង្រៀន ការពន្យល់បកស្រាយ និងឯកសារបណ្តុះបណ្តាល និងបន្តផ្សព្វផ្សាយអំពីកម្មវិធីសិក្សាជំនាញវិជ្ជាជីវៈពន្ធដារជូនដល់សមាជិកនៃសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា។ លោកនាយកបានបញ្ជាក់បន្ថែមថា ការធ្វើបច្ចុប្បន្នភាពចំណេះដឹងពាក់ព័ន្ធនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារគឺពិតជាមានសារៈសំខាន់មិនអាចខ្វះបាន ដើម្បីចូលរួមផ្សព្វផ្សាយនូវចំណេះដឹងស្តីពីពន្ធដារ ក៏ដូចជាវប្បធម៌នៃការបង់ពន្ធ ក្នុងការគាំទ្រដល់ការកៀរគរចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងគោលដៅបង្កើនចំណូលថវិកាជាតិ និងរក្សាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។

ជាកិច្ចបន្ទាប់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** ប្រធានសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា បានផ្តល់មតិចំណាប់អារម្មណ៍អំពីកិច្ចពិភាក្សា និងថ្លែងអំណរគុណចំពោះអគ្គនាយកដ្ឋានពន្ធដារ ដែលតែងតែផ្តល់កិច្ចសហការល្អ និងបង្កើតឱ្យមានកិច្ចពិភាក្សានេះឡើង។ ឯកឧត្តមបណ្ឌិតបានសម្តែងនូវការគាំទ្រយ៉ាងពេញទំហឹងដល់កិច្ចខិតខំប្រឹងប្រែងកំណែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដារ ដែលធ្វើឱ្យការប្រមូលចំណូលពន្ធដារជាថវិកាជាតិមានការកើនឡើងជារៀងរាល់ឆ្នាំ។ បន្ថែមពីនេះឯកឧត្តមបណ្ឌិតបានលើកឡើងអំពីកិច្ចសហការរវាងសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារពិតជាមានសារៈសំខាន់ក្នុងការពង្រឹងសមត្ថភាពគ្រូបង្រៀនមុខវិជ្ជាពន្ធដារនៅតាមបណ្តាគ្រឹះស្ថានឧត្តមសិក្សា និងជំរុញឱ្យមានសង្គតិភាពលើការបង្រៀន ការបកស្រាយ និងឯកសារបណ្តុះបណ្តាលឱ្យមានលក្ខណៈឯកសណ្ឋានភាព។

ជាលទ្ធផលនៃកិច្ចពិភាក្សា សមាជិកសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជាបានបង្ហាញអំពីការគាំទ្រឱ្យមានវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពគ្រូបង្រៀនមុខវិជ្ជាពន្ធដារសម្រាប់គ្រឹះស្ថានឧត្តមសិក្សា និងការរៀបចំឯកសារបណ្តុះបណ្តាលជារួមមួយ លើមុខវិជ្ជាពន្ធដារ ដើម្បីឱ្យការបង្រៀនមុខវិជ្ជាពន្ធដារនេះមានសង្គតិភាពទូទាំងប្រទេស។ បន្ថែមលើនេះ កិច្ចពិភាក្សាអនុញ្ញាតឱ្យស្ថាប័នទាំងពីរអាចសហការផ្សព្វផ្សាយ និងបណ្តុះបណ្តាលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារថ្មីៗ និងបញ្ជ្រាបវប្បធម៌បង់ពន្ធ ជូនដល់គ្រូ ក៏ដូចជាសិស្ស-និស្សិត និងសាធារណជន ដើម្បីបន្តនិរន្តភាពវប្បធម៌នៃការបង់ពន្ធ និងការប្រមូលចំណូលពន្ធ។ ជាងនេះទៅទៀត សមាជិកសមាគមគ្រឹះស្ថានឧត្តមសិក្សាដែលបានចូលរួមក្នុងកិច្ចពិភាក្សានេះក៏បានសំណូមពរឱ្យអគ្គនាយកដ្ឋានពន្ធដារបន្តរៀបចំឱ្យមានការជួបជុំពិភាក្សាគ្នាជាប្រចាំនៅពេលក្រោយៗទៀត។ កិច្ចពិភាក្សានេះ ត្រូវបានបញ្ចប់នៅម៉ោង ១១ : ៣០នាទី ថ្ងៃខែឆ្នាំដដែល ដោយទទួលបានលទ្ធផលជាផ្លែផ្កាក្រោមស្មារតីកិច្ចសហប្រតិបត្តិការ និងទទួលខុសត្រូវខ្ពស់៕